**ស្ថានទូតជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

**សេចក្តីប្រកាសព័ត៌មាន**

លេខ.64 PR-19/EoJ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

# ជប៉ុនផ្តល់ ៤៣៩,២៦១ ដុល្លារអាមេរិក សម្រាប់គម្រោងលើកកម្ពស់ការអភិវឌ្ឍសហគមន៍តាមរយៈការបោសសម្អាត មីន គាំទ្រកច្ចសហប្រតិបត្តការកសិកម្មនិងការពង្រឹងការថែទាំសុខភាពក្នុងសហគមន៍

រដ្ឋាភិបាលជប៉ុន បានឯកភាពផ្តល់ថវិកាសរុបចំនួន ៤៣៩,២៦១ ដុល្លារអាមេរិក ដល់អង្គការIVY ក្រោមគ្រោងការណ៍ជំនួយហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ**ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង **លោកស្រី ឈីហ្សកុ ស៊ីហ្សឹះស៊ីម៉ាក** ជំនួយការនាយកនៃអង្គការ IVY ដើម្បីអនុវត្តគម្រោង"គាំទ្រកសិករខ្នាតតូចធ្វើកសិកម្មតាមកិច្ចសន្យាលើដំណាំស្វាយចន្ទីសរីរាង្គតាមរយៈសហគមន៍កសិកម្ម (ឆ្នាំទី ២)" ។

សព្វថ្ងៃ ផលិតផលកសិកម្មសរីរាង្គកាន់តែមានប្រជាប្រិយភាពនៅលើទីផ្សារហើយផលិតផលទាំងនោះត្រូវបានលក់ក្នុងតម្លៃខ្ពស់។ ក្នុងគម្រោងនេះអង្គការIVY នឹងគាំទ្រដល់កសិករនិងសហគមន៍កសិកម្មក្នុងស្រុក (AC) ក្នុងខេត្តព្រះវិហារ ដូច្នេះកសិករអាចផលិតនិងលក់គ្រាប់ស្វាយចន្ទីសរីរាង្គដែលមានតម្លៃបន្ថែម និងទទួលបានប្រាក់ចំណូលបន្ថែមទៀតដើម្បីគេចផុតពីភាពក្រីក្រ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តារបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ មករដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង៣៧លានដុល្លារអាមេរិក ដល់គម្រោងចំនួន១២២ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៩-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

សុន្ទរកថារបស់ **ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ**
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយក្នុងគម្រោងហិរញ្ញប្បទានឥតសំណងសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។
២៩ វិច្ឆិកា ២០១៩

- សូមគោរព លោកស្រី ឈីហ្វុកុ សឹហ្ស៊ឺះស៊ីម៉ាក  ជំនួយការនាយកនៃអង្គការ IVY
- សូមគោរព លោក លោកស្រី ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី!

ជំរាបសួរ! ខ្ញុំឈ្មោះ មិកាមិ ឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជា។
ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបាន រៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយក្នុងគម្រោងហិរញ្ញប្បទានឥតសំណងសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុនទៅដល់អង្គការ IVY។

លើកនេះ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាប្រមាណ ៩៤ ម៉ឺនដុល្លារសហរដ្ឋអាមេរិកដល់អង្គការ IVY។ ខេត្តព្រះវិហារជាខេត្តដែលអង្គការកំពុងធ្វើសកម្មភាពនេះ ជាខេត្តមួយក្នុងចំណោមខេត្តដែលមានអត្រាភាពក្រីក្រខ្ពស់នៅកម្ពុជា ដូច្នេះការកាត់បន្ថយភាពក្រីក្រមានសារៈសំខាន់ណាស់។ នៅក្នុងខេត្តព្រះវិហារ គម្រោងនេះកំពុងតែគាំទ្រនិងខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ប្រាក់ចំណូលរបស់កសិករ តាមរយៈការយកចិត្តទុកដាក់ទៅលើគ្រាប់ស្វាយចន្ទីដែលបានដាំដុះយ៉ាងសកម្មក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ធ្វើការណែនាំពីការដាំដុះសរីរាង្គដល់កសិករ និងការដឹកជញ្ជូនរួមគ្នាតាមរយៈសហគមន៍កសិកម្ម។ នៅឆ្នាំនេះ អង្គការនឹងធ្វើការអនុវត្តគម្រោងដើម្បីឲ្យសហគមន៍កសិកម្មចំនួន៦ថែមទៀតទទួលបានវិញ្ញាបនបត្រសរីរាង្គ ហើយក៏ខិតខំប្រឹងប្រែងបង្កើនបច្ចេកទេសរបស់កសិករ តាមរយៈការណែនាំបច្ចេកទេសដាំដុះថ្មី ដូចជាការផ្សាំឈើ និង កាត់មែកដែលមិនចាំបាច់ចេញ។ យើងរំពឹងថាប្រាក់ចំណូលរបស់កសិករនឹងកើនឡើងកាន់តែខ្លាំងដោយកសិករគោលដៅនឹងអាចដាំដុះគ្រាប់ស្វាយចន្ទីដែលមានតម្លៃបន្ថែមក្នុងនាមជាដំណាំសរីរាង្គប្រកបដោយស្ថេរភាព។

ជាទីបញ្ចប់ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និង សូមឲ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។
សូមអរគុណ។